# ព្រឹត្តិបត្រព័ត៌មាន

# BI-WEEKLY BULLETIN

លេខទី៤៨ ឆ្នាំ២០២១ (ថ្ងៃទី១៧ ដល់ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១)

CRF2021/048 (17 to 30 May 2021)

## *សង្ខេបព័ត៌មានសំខាន់ៗអំពីវិស័យស្រូវអង្ករប្រចាំសប្តាហ៍ (Rice News Briefing)*

## ក្នុងប្រទេស (In Cambodia)



### ស្រូវអូអឹម ៥៤៥១ ផ្តល់នូវលទ្ធផលគាប់ប្រសើរ

### OM 5451 rice delivers golden results

*Phnom Penh Post: 20 May 2021*

Booming demand in the Vietnamese market has taken prices of OM 5451 paddy on a wild ride during and beyond the dry-season rice harvest season this year, according to industry insiders.

OM 5451 is a high-yielding long-grain cultivar of fragrant rice mainly grown in the Mekong Delta, created by a crossbreed combination of Jasmine 85 and OM 2490 varieties for pest and disease resistance. (Read more)



### កម្ពុជាគ្រោងបន្ថែមម៉ាកសញ្ញាអង្ករ២ប្រភេទថែមទៀត ដើម្បីពង្រីកទីផ្សារនាំចេញ

### Cambodia to add 2 more rice brand for expand the exports market

*Rasmei Kampuchea: 20 May 2021*

សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) និងសហគ្រិនខ្មែរ (Khmer Enterprise) ដែលជាកម្មវិធីមួយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ជួយដល់សហគ្រាសក្នុងស្រុកក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផល សេដ្ឋកិច្ច និង ពាណិជ្ជកម្ម កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១កន្លងទៅនេះ បានបើកកិច្ចប្រជុំរួមគ្នាមួយ ដើម្បីពិភាក្សាគ្នាលើ ការធ្វើទីផ្សារ និងផ្សព្វផ្សាយអង្ករ កម្ពុជា ដើម្បីពង្រីកទីផ្សារនាំចេញ។ (Read more)



### សហព័ន្ធស្រូវអង្ករកម្ពុជា និងសហគ្រិនខ្មែរ កំពុងពិចារណាអំពីការធ្វើទីផ្សារអង្ករនាំចេញអន្តរជាតិ

### CRF, KE consider international milled-rice marketing linkup

*Phnom Penh Post: 24 May 2021*

The Cambodia Rice Federation (CRF) may soon strike a deal with Khmer Enterprise (KE) to work on the marketing and branding of Cambodian milled rice to reach a wider audience at international markets.

The two sides held a first meeting last week via video link to brainstorm ideas for a potential collaborative relationship to boost sales of the main linchpin of Cambodian (Read more)



### កម្ពុជា និងសាំងហ្គាពួរ នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម

### Cambodia, Singapore to further strengthen trade cooperation

*Khmer Times: 24 May 2021*

Cambodia and Singapore have reaffirmed their commitment to further strengthen their close relations and cooperation in all sectors, especially trade area.

The reaffirmation was made while Pan Sorasak, Minister of Commerce, received a courtesy call from newly appointed Singaporean Ambassador to Cambodia Ms. Teo Lay Cheng at the ministry office. (Read more)



## ការប្រមូលផលស្រូវរដូវប្រាំងឡើងដល់ ៣ លានតោន
## Up to three million tonnes of dry-season paddy rice harvested

*Khmer Times: 26 May 2021*

Some 2.93 million tonnes of paddy rice farmed during the dry-season were harvested in the first five months of this year and 1.60 million tonnes exported, a year-on-year increase of about 751,496 tonnes compared to 2020.

The figures were provided in a report released yesterday by the Ministry of Agriculture, Forestry and Fisheries. (Read more)



## ក្រសួងកសិកម្មដាក់ឱ្យអនុវត្តពាក្យស្នើសុំអាជ្ញាប័ណ្ណ និងលិខិតផ្សេងៗតាមទម្រង់អេឡិចត្រូនិក
## Ministry of Agriculture launch the application submit for license and other documents electronically

*Post Khmer: 27 May 2021*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចដាក់ឱ្យអនុវត្តជំហានដំបូងលើមុខងារស្នើសុំអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រ ក្នុងទម្រង់អេឡិចត្រូនិកដើម្បីបង្កលក្ខណៈងាយស្រួលដល់ម្ចាស់អាជីវកម្ម និងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្មផងដែរ។ ( Read more )



# អន្តរជាតិ ( International )



ហ្វីលីពីន ( Philippines )

## ការកាត់បន្ថយពន្ធអង្ករបង្កើនបរិមាណនាំចូលជា"រឿងកំប្លែងដ៏សាហាវ"
## Lowering rice tariffs, raising import volume a ‘cruel joke’

*Inquirer Net: 17 May 2021*

MANILA, Philippines—The recent presidential directive lowering tariffs on rice imports from non-Asean countries was a cruel joke on rice farmers made right in the middle of Farmers’ Month and the feast day of Saint Isidore, the patron saint of Filipino farmers. Executive Order No. 135 was issued on May 15, 2021 lowering both the 50 percent out-quota and the 40 percent minimum access volume (MAV) tariffs on rice imports to 35 percent for one year. The adjustment, which was recommended by the National Economic and Development Authority (Neda) Board, was purportedly intended to “diversify the country’s market sources, augment rice supply, maintain prices affordable and reduce pressures on inflation”. (Read more)



ហ្វីលីពីន ( Philippines )

## រដ្ឋាភិបាលនឹងបញ្ឈប់ការនាំចូលអង្ករក្នុងរដូវប្រមូលផលក្នុងស្រុក
## Gov’t to suspend rice importation during local harvest season



*Manila Bulletin: 20 May 2021*

The government intends to halt rice importation during the local harvest season to help protect farmers, according to a Palace official. Presidential spokesman Harry Roque explained that rice importation will only be carried out after the domestic harvest has been completed. (A notice to our producers but we will not import during the harvest season. We will wait for the harvest period to end so the farmers’ selling price in the market will not be affected),” Roque said during a televised press briefing Thursday, May 20. (Read more)



ប៉ាគីស្ថាន ( Pakistan )

## តើកាលីហ្វ័រញ៉ាធ្វើយ៉ាងដូចម្តេចដើម្បីបង្កើតការផលិតស្រូវអង្ករប្រកបដោយនិរន្តរភាព
## How California is making rice farming sustainable



*Profit: 23 May 2021*

ISLAMABAD: Following the government’s request to farmers for limiting the production of Basmati rice, exporters have express serious concerns and called the decision completely irrational.

In this regard, Prime Minister’s Task Force on Agriculture Chairman, Jamshed Iqbal Cheema, during a press conference regarding the agriculture reform package had said that the export market mostly required coarse rice but Pakistani farmers were addicted to Basmati (Read more)

## IRRI និង Biotech ជាដៃគូសហការក្នុងការអភិវឌ្ឍប្រភេទស្រូវដែលធន់ទ្រាំនឹងគ្រោះរាំងស្ងួត

## IRRI, biotech partner to develop rice varieties resistant to drought



*Business World 24 May 2021*

THE International Rice Research Institute (IRRI) has entered into a partnership with Bioseed Research Philippines, Inc. to develop rice varieties for the Philippines which are resilient in drought and flood conditions.

Gururaj Guddappa Kulkarni, IRRI Bio-Innovation Center and Global head of Research Infrastructure and Compliance, said in an e-mail interview with BusinessWorld: (Read more)



បង់ក្លាដេស ( Bangladesh )

## ដំណាំស្រូវរបស់បង់ក្លាដែសត្រូវបានបំផ្លាញដោយភាពតានតឹងកម្តៅ ៣៦ អង្សាសេ

## Bangladesh rice crop wiped out by heat stress at 36°C



*Business Day: 28 May 2021*

Bangladesh — Standing in his paddy field in northeast Bangladesh, Shafiqul Islam Talukder holds a handful of empty stalks — all chaff, with no rice grains.

Two days of sudden, intensely hot air that swept across the country in April disrupted the rice's growth, destroying the crop his family was supposed to survive the year on, the farmer from Kishoreganj district said. (Read more)



ឥណ្ឌា ( India )

## ឥណ្ឌាគ្រោងនាំចេញអង្ករទៅហ្វីលីពីនបន្ទាប់ពីការកាត់បន្ថយពន្ធនាំចូលដល់ ៣៥ ភាគរយ

## India set to export rice to the Philippines after reduction of import duty to 35%



*Economic Times: 28 May 2021*

India's rice exporters are gearing up to ship the grain to the Philippines from next month as the Southeast Asian nation has reduced the import duty on rice being shipped from India to 35% from 50%. Philippines is the second-largest importer of the commodity in the world.

"We will be exporting non-basmati rice to the country. We are currently looking into the modalities of export to Philippines," president of the Rice Exporters Association, BV Krishna Rao, (Read more)



ថៃ ( Thailand )

## ប្រទេសថៃស្វែងរកពូជស្រូវថ្មី ដើម្បីដណ្តើមយកមកវិញនូវតំណែងជាជើងឯកនាំចេញអង្ករ

## Thailand seeks new rice varieties to reclaim position as rice export champ



*Pattaya Mail: 29 May 2021*

The Thai government is now working with private firms to select and promote new varieties of Thai rice for export, as the Thai rice export figure has been in decline since last year.

The Rice Department and Thai Rice Exporters Association (TREA) are seeking new varieties of Thai rice that could gain popularity with international customers and allow Thailand to reclaim its position as the rice export champion. (Read more)




# កិច្ចពិភាក្សាស្វែងយល់លទ្ធភាពក្នុងការសហការរវាងសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) និងសហគ្រិនខ្មែរ (Khmer Enterprise) លើការធ្វើទីផ្សារនិងផ្សព្វផ្សាយ (Marketing and Branding) អង្ករកម្ពុជា ដើម្បីពង្រីកទីផ្សារនាំចេញ

នាព្រឹកថ្ងៃពុធ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ **លោកស្រី គឹម ស្រីរ័ត្ន** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងជាប្រធានគណៈកម្មការប្រតិបត្តិផ្នែកទីផ្សារ និងជំរុញការនាំចេញ រួមជាមួយលោក **លន់ យ៉េង** អគ្គលេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជា និងសហការី បានជួបពិភាក្សាតាមរយៈអនឡាញជាមួយនឹងសហគ្រិនខ្មែរ ដែលមាន **លោក គង់ សុភីវឌ្ឍនៈ** ប្រធានផ្នែកទីផ្សារ និងការវិនិយោគរបស់សហគ្រិនខ្មែរ និងសហការី ដែលកិច្ចពិភាក្សានេះគឺធ្វើឡើងដើម្បីស្វែងយល់អំពីលទ្ធភាពក្នុងការសហការគ្នា លើការពង្រីកទីផ្សារនាំចេញអង្ករកម្ពុជា ដែលផ្តោតលើការងារទីផ្សារ និងការងារផ្សព្វផ្សាយលើឆាកអន្តរជាតិ ដែលពិតជាមានសារៈសំខាន់ និងផ្តល់នូវប្រសិទ្ធភាពខ្ពស់ក្នុងការបញ្ជ្រាបអំពីកិត្តិនាមអង្ករកម្ពុជាប្រកបដោយគុណភាព។

**សូមបញ្ជាក់ថា ៖** សហគ្រិនខ្មែរ ជាកម្មវិធីមួយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ជួយដល់សហគ្រាសក្នុងស្រុកក្នុងការលើកកំពស់ប្រសិទ្ធភាព និងប្រសិទ្ធផលសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។

នៅក្នុងជំនួបលើកដំបូងនេះ តាងនាមឱ្យសហព័ន្ធស្រូវអង្ករកម្ពុជា លោកស្រី គឹម ស្រីរ័ត្ន បានសម្តែងនូវការអរគុណចំពោះការគាំទ្រយ៉ាងខ្លាំងក្លារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសហគ្រិនខ្មែរជាអង្គភាពស្ថិតក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មកកាន់វិស័យឯកជនតាមរយៈជំនួយជាកញ្ចប់ថវិកា និងបច្ចេកទេសនានា ជាពិសេសគឺការចាប់អារម្មណ៍មកលើវិស័យស្រូវអង្ករ ក្នុងការងារទីផ្សារ និងការផ្សព្វផ្សាយ ដែលនាំឱ្យមាននូវកិច្ចពិភាក្សានៅថ្ងៃនេះឡើង។

លោកប្រធានផ្នែកទីផ្សារនិងវិនិយោគរបស់សហគ្រិនខ្មែរ ក៏បានបង្ហាញនូវការចាប់អារម្មណ៍ខ្ពស់ លើទីផ្សារស្រូវអង្ករកម្ពុជា ជាពិសេសលើការធ្វើម៉ាកសញ្ញាអង្ករដែលសហព័ន្ធបានធ្វើកន្លងមក គឺម៉ាកម្លិះអង្ករ។ បន្ថែមលើម៉ាកម្លិះអង្ករនេះ សហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានលើកជាសំណើរក្នុងការស្វាគមន៍នូវកិច្ចសហការជាមួយនឹងសហគ្រិនខ្មែរ លើការផ្សព្វផ្សាយនិងធ្វើទីផ្សារប្រភេទអង្ករ២បន្ថែមទៀត គឺសែនក្រអូប និងដំណើបស្បៃមង្គល ដែលក្នុងខណៈពេលនេះ សហព័ន្ធស្រូវអង្ករកម្ពុជា បាននិងកំពុងតែចាប់ផ្តើមនូវគម្រោងចុះបញ្ជីម៉ាកសមូហភាព (Collective Mark) និងសម្ភោធម៉ាកទាំង២នេះ ក្រោមការគាំទ្រពីរាជរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្ម កម្ពុជា-អូស្ត្រាលី។

ជាការងារបន្តទៅមុខជាមួយគ្នាទៀត សហព័ន្ធស្រូវអង្ករកម្ពុជា នឹងធ្វើជាសំណើរ (Proposal) ទៅកាន់សហគ្រិនខ្មែរ លើការងារជាក់លាក់ផ្នែកទីផ្សារ និងផ្សព្វផ្សាយ ដែលផ្តោតលើគោលបំណងសំខាន់ គឺពង្រីកទីផ្សារនាំចេញ ដើម្បីបង្កើននូវកេរ្តិ៍ឈ្មោះផលិតផលខ្មែរ ទាំងក្នុងប្រទេស និងក្រៅប្រទេស។

Click here for English article:
Discussion on the possibility to cooperate between CRF and Khmer Enterprise (KE) on marketing and branding Cambodian Rice for expand export's market

# កិច្ចពិភាក្សាតុមូលស្ដីពី ការធ្វើពាណិជ្ជកម្មលើផលិតផល អាហារដែលមានបញ្ចូលមីក្រូសារជាតិ

នាថ្ងៃព្រហស្បតិ៍ ៩កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ **ឧកញ៉ា សុខ សារ៉ន** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមថ្លែងសុន្ទរកថាបើកកិច្ចពិភាក្សាស្ដីពី ការធ្វើពាណិជ្ជកម្មលើផលិតផលអាហារដែលមានបញ្ចូលមីក្រូសារជាតិ ក្រោមអធិបតីភាព **ឯកឧត្តម សុខ ស៊ីឡូ** អគ្គលេខាធិការនៃក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ(CARD) MS. RANA KARADSHEH នាយកឧស្សាហកម្មប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation-IFC) និង លោក ASAD YAQUB អ្នកតំណាង IFC ប្រចាំកម្ពុជា ហើយក៏មានការចូលរួមចំនួន ៦០នាក់ ដែលក្នុងនោះសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា ដែលជាក្រុមហ៊ុននាំចេញ រោងម៉ាស៊ីនកិនស្រូវ ប្រមាណជា២០ក្រុមហ៊ុន និងវាគ្មិនដែលជាអ្នកជំនាញផ្នែកជាតិ និងអន្តរជាតិ អញ្ជើញមកពីស្ថាប័ននានា ដែលពាក់ព័ន្ធ ដើម្បីចូលរួមចែករំលែកអំពីបទពិសោធន៍ នៅក្នុងកិច្ចពិភាក្សានេះ។

កិច្ចពិភាក្សានេះត្រូវបានរៀបចំឡើងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ នៃធនាគារពិភពលោក ក្រោមការសហការគាំទ្រដោយ CARD និងសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) និងកម្មវិធីសុវត្ថិភាពកសិកម្មនិងចំណីអាហារជាសកល (GLOBAL AGRICULTURE AND FOOD SECURITY PROGRAM) ដែលកិច្ចពិភាក្សានេះមានគោលបំណងសំខាន់ ដើម្បីសិក្សាអំពីជម្រើសសម្រាប់ការធ្វើពាណិជ្ជកម្មនៃផលិតផលអាហារ ក៏ដូចជាអង្ករដែលមានបញ្ចូលមីក្រូសារជាតិ និងដើម្បីកំណត់តួអង្គសំខាន់ៗនៅក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ដែលបានត្រៀមខ្លួនចូលរួមក្នុងកិច្ចការងារនេះ និងលើកទឹកចិត្តជាពិសេសដល់វិស័យឯកជនពិនិត្យលទ្ធភាពក្នុងការបញ្ចូលមីក្រូសារជាតិនៅក្នុងអាហារ។

ជាការចូលរួម ក្នុងការបើកនូវកិច្ចពិភាក្សានេះ ក្រៅពីការលើកឡើងអំពីសាវតាររបស់សហព័ន្ធស្រូវអង្ករកម្ពុជា ឧកញ៉ា សុង សារ៉ន បានរំលេចអំពីការគាំទ្រយ៉ាងសកម្ម និងប្រកបដោយប្រសិទ្ធភាពកន្លងមករបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ IFC នៃធនាគារពិភពលោក តាមរយៈកម្មវិធីធ្វើឱ្យប្រសើរឡើងផ្នែកនាំចេញអង្ករ។ គួររំលឹកផងដែរថា កម្ពុជាបាននាំចេញត្រឹមតែជាងមួយម៉ឺនតោន នៅឆ្នាំ២០០៩ ហើយក៏បានកើនឡើងដល់លើស៦០ម៉ឺនតោន នៅក្នុងឆ្នាំ២០២០។ ឧកញ៉ា ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានបន្ថែមទៀតថា ការរីកចម្រើនរបស់វិស័យស្រូវអង្ករកម្ពុជា សម្រាប់តែអង្ករធម្មតាមួយមុខ គឺមិនគ្រប់គ្រាន់នោះទេ ដែលបច្ចុប្បន្ននេះ សហព័ន្ធស្រូវអង្ករកម្ពុជាបាននិងកំពុងរិះរកកម្មវិធីយុទ្ធសាស្ត្រ និងកំពុងចូលរួមយ៉ាងសកម្មក្នុងការធ្វើឱ្យបានលក្ខណៈជាពិពិធកម្មពាណិជ្ជកម្មលើប្រភេទអង្ករ និងទីផ្សារ ដែលក្នុងនោះអង្ករដែលមានបញ្ចូលមីក្រូសារជាតិ ជាផ្នែកមួយយ៉ាងសំខាន់ផងដែរ សម្រាប់បងប្អូនរោងម៉ាស៊ីនកិនស្រូវ និងអ្នកធ្វើពាណិជ្ជកម្មអង្ករ សម្រាប់ពង្រីក និងបំបែកទីផ្សារចេញ អំពីការធ្វើពាណិជ្ជកម្មអង្ករធម្មតា។ រយៈកាលកន្លងមក មានរោងម៉ាស៊ីនកិនស្រូវដែលជាសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមក្នុងកម្មវិធីនេះមួយចំនួនហើយ គឺតាមរយៈកម្មវិធីស្បៀងអាហារពិភពលោក



(World Food Program) និងកម្មវិធីផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដែលជាផ្នែកមួយ ក្នុងការចូលរួមលើកកម្ពស់នូវកម្រិតអាហារូបត្ថម្ភសម្រាប់ប្រជាជន ដែលចាំបាច់ត្រូវទទួលបាននូវចំណីអាហារ ដែលមានវីតាមីន។

មុននឹងបញ្ចប់សុន្ទរកថា ឧកញ៉ា ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានគូសបញ្ជាក់បន្ថែមទៀតផងដែរថា សម្រាប់សហព័ន្ធនិងសមាជិកទាំងអស់ពិតជាគាំទ្រ នូវកម្មវិធីបញ្ចូលមីក្រូសារជាតិនៅក្នុងអង្ករនេះទាំងស្រុងនិងជឿជាក់ថាតាមរយៈបទពិសោធន៍នៃការអនុវត្តគម្រោងរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) កន្លងមក កម្មវិធីនេះនឹងអាចសំរេចទៅមុខបានដោយជោគជ័យ ដែលនឹងផ្តល់នូវផលចំណេញដល់គ្រប់ភាគី ទាំងវិស័យសាធារណៈដែលបានចំណេញពីការវិនិយោគចំទិសដៅលើផ្នែកសុខភាពសាធារណៈ ផ្នែកឯកជនទទួលបាននូវប្រាក់ចំណេញ និងនិរន្តភាពពីការធ្វើពាណិជ្ជកម្មនៃការលាយអង្ករវីតាមីន និងលក់លើទីផ្សារទាំងក្នុងស្រុក និងនាំចេញ ហើយប្រជាជនក៏បានទទួលនូវសុខភាពល្អពីការទទួលទាននូវចំណីអាហារ ដែលមានសុវត្ថិភាពនិង មានវីតាមីនល្អដែលចាំបាច់សម្រាប់ប្រជាជនដែលខ្វះខាត (5 Ps= Profit to Public, Private and Poor People)។

កិច្ចពិភាក្សានេះបានរួមបញ្ចូលនូវប្រធានបទសំខាន់ៗចំនួន៤ ដែលមានការចូលរួមចែករំលែកពីវាគ្មិន អ្នកជំនាញជាតិ និងអន្តរជាតិ លើបទពិសោធន៍ជោគជ័យនៃការបញ្ចូលមីក្រូសារជាតិនៅក្នុងអង្ករ និងទីផ្សារអង្ករប្រភេទនេះ និងជាពិសេសនោះ ក៏មានការចូលរួមចែករំលែកពីបទពិសោធន៍របស់សមាជិកក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា និងជាអគ្គនាយកក្រុមហ៊ុន Indochina Rice Mill លោក យន់ ហុង លើប្រធានបទតុអង្គពាក់ព័ន្ធពីវិស័យឯកជនដើម្បីបង្ហាញពីចំណាប់អារម្មណ៍ក្នុងពាណិជ្ជកម្មអង្ករលាយមីក្រូសារជាតិនៅក្នុងប្រទេសកម្ពុជានេះ។










Click here for English article: Commercialization of Food Fortification Roundtable

# តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
# (Paddy price & FOB Price)

## តម្លៃស្រូវ នៅវាលស្រែ ដែលកំពុងប្រមូលផល តាមបណ្ដាខេត្តមួយចំនួន

ថ្ងៃចន្ទ ទី៣១ ខែឧសភា ឆ្នាំ២០២១

គិតជារៀល/គីឡូក្រាម

| ខេត្ត | ស្រុក | សែនក្រអូប | អូអឹម ៥៤៥១ | អ៊ីអ៊ែរ ៨៥ | ផ្សេងៗ |
|---|---|---|---|---|---|
| កំពង់ធំ | កំពង់ស្វាយ | | 920-950 | | |
| | ស្ទោង | | 920-950 | | |
| | សន្ទុក | | 920-950 | | |
| បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 1070-1100 | 920-930 | 910-930 | |
| | ភ្នំស្រុក | 1070-1100 | 920-930 | | |
| បាត់ដំបង | បាណន់ | 1080-1140 | | | 1000-1050 |
| ពោធិ៍សាត់ | ក្រគរ | | 890-910 | 890-920 | |
| កំពង់ឆ្នាំង | កំពង់លែង | | 920-950 | | |
| | បរិបូណ៌ | | 890-910 | 890-920 | |
| | កំពង់ត្រឡាច | | 930-950 | 930-950 | |
| ព្រៃវែង | ពារាំង | | 900-950 | | |
| | ស្វាយអន្ទរ | | 900-950 | | |
| តាកែវ | អង្គរបុរី | | 920-950 | | |

**ប្រភពទិន្នន័យ**

- សហគមន៍កសិកម្មនៅតាមបណ្ដាខេត្ត
  ១. ស្រុកបាណន់ ខេត្តបាត់ដំបង (097 825 6557)
  ២. ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង (089 509 232)
  ៣. ស្រុកពារាំង ខេត្តព្រៃវែង (097 4968 066)
  ៤. ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង (012 193 4283)
- Agribee Cambodia PLC (096 77 00 111)

## សហព័ន្ធស្រូវអង្ករកម្ពុជា
## Cambodia Rice Federation

**តម្លៃអង្ករនាំចេញ FOB Price**
as of 18 May 2021

| Rice Varieties | Rice Standard (Price USD/ MT) 5% |
|---|---|
| Jasmine Rice (Malys Angkor) | 800 |
| Standard Fragrant Rice_SKO | 770 |
| White Rice_Premium (Soft cooking) | 550 |
| Parboiled Rice | 580 |
| Organic Parboiled Rice (Premium Quality) | 990 |
| Organic White Rice (Premium Quality) | 920 |
| Organic Jasmine (Malys Angkor) | 1380 |
| Organic Brown Jasmine (Premium Quality) | 1350 |

**Source :** Cambodian Exporters and Millers
**Note:** Price Fluctuation : +/- 2%


**សហព័ន្ធស្រូវអង្ករកម្ពុជា (Cambodia Rice Federation)**

**ប្រធានក្រុមប្រឹក្សាភិបាល (Chairman)**
*លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)*

**ប្រធានសហព័ន្ធ (President)**
*លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)*

**អគ្គលេខាធិការ (Secretary General)**
*លោក លន់ យ៉េង (Mr. Lun Yeng)*

**រៀបរៀងដោយ (Prepared by)**
*កញ្ញា សន ធវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*

+855 23 559 8999
info@crf.org.kh
www.crf.org.kh
www.facebook.com/cambodiaricefederation
twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation